សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៤៣ ខែមេសា-ឧសភា ឆ្នាំ២០០៩
Issue: 43 April-May 2009

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# ការផ្លាស់ប្តូរមន្ត្រីរបស់សាលាក្តីខ្មែរក្រហម

## Changes in Officials' Positions at the Khmer Rouge Tribunal

នៅខណៈពេលដែលសាលាក្តីខ្មែរក្រហម បាននិងកំពុងធ្វើការជំនុំជម្រះសេចក្តីទៅលើអតីតប្រធានគុកទួលស្លែង **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**" ការផ្លាស់ប្តូរនូវមន្ត្រីរបស់សាលាក្តីមួយចំនួនត្រូវបានធ្វើឡើងជាផ្នែកមួយនៃការពង្រឹងគុណភាពការងាររបស់សាលាក្តីនេះ។ យោងទៅតាមសេចក្តីប្រកាសព័ត៌មាន ដែលបានចេញផ្សាយជាផ្លូវការរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ២០០៩ កន្លងមកនេះ បានគូសបញ្ជាក់ថា លោកស្រី **ហេឡេន ចារវីស** ដែលជាប្រធានការិយាល័យកិច្ចការសាធារណៈ នឹងត្រូវទៅធ្វើជាប្រធានថ្មីនៃអង្គភាពជនរងគ្រោះ ក្រោយពីការសុំលាលែងរបស់ប្រធានបច្ចុប្បន្នលោកស្រី **គាត បូផល**។ នៅទន្ទឹមពេលនេះដែរ លោក **រាជ សម្បត្តិ** ជាមន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ត្រូវបានតែងតាំងឱ្យធ្វើជាប្រធានការិយាល័យកិច្ចការសាធារណៈ ជំនួសលោកស្រី **ហេឡេន** ដែលមុខនាទីនេះនឹងចូលជាធរមានចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៩ ខាងមុខនេះ។ ចំណែកឯលោក **ឌឹម សុវណ្ណារុំ** ដែលជាមន្ត្រីមកពីទីស្តីការគណៈរដ្ឋមន្ត្រីនឹងមកជំនួសតំណែងរបស់លោក **រាជ សម្បត្តិ** ក្នុងឋានៈជាមន្ត្រីទទួលបន្ទុកព័ត៌មាន។ ជាមួយគ្នានេះ លោក **ឡាស អូលសិន** ដែលជាជនជាតិណរវ៉ែស ក៏ត្រូវបានតែងតាំងតាំងពីខែមីនា ឆ្នាំ២០០៩ ជំនួសលោក **ភីធើ ហ្វូស្ទ័រ** ដែលបានសុំលាលែងសំរាប់ធ្វើ ជាមន្ត្រីទទួលបន្ទុកទំនាក់ទំនងផ្លូវច្បាប់របស់សាលាក្តីខ្មែរក្រហមនេះ។

ជាមួយនឹងការវិវត្តន៍លើការផ្លាស់ប្តូរមន្ត្រីសាលាក្តីនេះ ក៏មានការវិវត្តន៍ជាវិជ្ជមានគួរឱ្យកត់សំគាល់ផងដែរនោះ គឺការផ្តល់វិភាគទាន បន្ថែមដល់ភាគីកម្ពុជា នៃសាលាក្តី ដោយរាជរដ្ឋាភិបាលជប៉ុនចំនួនជាង ៤លានដុល្លារសហរដ្ឋអាមេរិក ដែលអនុញ្ញាតសាលាក្តីនេះ មានលទ្ធភាពការងារបន្តទៅមុខទៀត។



ចៅក្រម នៃ អង្គជំនុំជម្រះសាលាដំបូងនៅពេលបើកសវនាការ ឌុច

ប៉ុន្តែទន្ទឹមនឹងនេះ អ្វីដែលនៅបន្តជាបញ្ហា ព្រួយបារម្ភនៅឡើយនោះគឺ ការមិនទាន់ឯកភាពគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទៅលើយន្តការដោះស្រាយការចោទប្រកាន់អំពីអំពើពុករលួយ ដែលចាំបាច់ត្រូវតែធ្វើឡើង។

# អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម បន្តកាត់សេចក្តីអតីតមេគុកទួលស្លែង

## ECCC's Trial Chamber Continues Trials of Former Chief of Tuol Sleng Torture Center

បន្ទាប់ពីបានចាប់ផ្តើម តាំងពីចុងខែមីនា ឆ្នាំ២០០៩ កន្លងមក អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តដំណើរការតទៅទៀតទៅលើសំណុំរឿង ០០១ ដែលមានជនជាប់ចោទអតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**"។

អង្គជំនុំជម្រះសាលាដំបូង ដែលមានសមាសភាពចៅក្រមជាតិចំនួន៣រូប និងចៅក្រមអន្តរជាតិចំនួន ២រូប ដឹកនាំដោយលោកចៅក្រម **និល ណុល** បានបន្តកាត់សេចក្តីទៅលើជនជាប់ចោទ **ឌុច** បន្ទាប់ពីមានការចេញដីកាបញ្ជូនរឿងឱ្យជំនុំជម្រះដោយសហចៅក្រមស៊ើបអង្កេតក្រោមបទចោទប្រកាន់ថា **ឌុច** គឺជាអ្នកទទួលខុសត្រូវខ្ពស់ បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស

ឧក្រិដ្ឋកម្មទាក់ទិននឹងមន្ទីរស-២១ ជាទីដែលមានអ្នកទោសប្រមាណជាង ១,៦០០០នាក់ ត្រូវបានធ្វើទារុណកម្ម និងសំលាប់យ៉ាងព្រៃផ្សៃបំផុតនៅពេលជនជាប់ចោទរូបនេះធ្វើជាប្រធានមន្ទីរសន្តិបាលនេះ។

យោងទៅតាមដីកាចោទប្រកាន់សន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត **ឌុច** ត្រូវបានចោទប្រកាន់ពី *បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនឹងអនុសញ្ញាក្រុងហ្សឺណែវ (ឧក្រិដ្ឋកម្មសង្គ្រាម) និងបទល្មើសថ្នាក់ជាតិ គឺអំពើមនុស្សឃាត និងអំពើទារុណកម្ម* ក្រោយពីបានធ្វើការស៊ើបអង្កេតអស់រយៈពេលជិត១ឆ្នាំ បន្ទាប់ពីបានទទួលដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលចេញដោយសហព្រះរាជអាជ្ញា កាលពីខែកក្កដា ឆ្នាំ២០០៧ ។ ដូចនេះ សវនាការដែល បានកំពុងប្រព្រឹត្តធ្វើឡើងក្រោមក្រសែភ្នែកតាមដានយ៉ាងយកចិត្តទុកពីសំណាក់ប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស និងនៅក្រៅប្រទេស និងអន្តរជាតិនាពេលនេះ គឺដើម្បីកាត់សេចក្ដីទៅលើជនជាប់ចោទរូបនេះ ថាតើពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់នេះ ឬអត់។

លើសពីនេះទៅទៀត អ្វីដែលជាការកត់សំគាល់ខ្លាំងដោយមជ្ឈដ្ឋានអ្នកចូលរួមតាមដានផ្ទាល់ និងសារព័ត៌មានជាតិ និងអន្តរជាតិ ទៅលើសវនាការកាត់សេចក្ដីនាសប្ដាហ៍កន្លងមកនេះ គឺថា អតីតមេគុកទួលស្លែង **ឌុច** *"បានឆ្លើយសារភាពទទួលកំហុសរបស់ខ្លួនចំពោះ ឧក្រិដ្ឋកម្មទាំងឡាយ ដែលបានកើតឡើងនៅក្នុងវង្វង់នៃការទទួលខុសត្រូវរបស់គាត់ និងបានសុំអភ័យទោសចំពោះជនរងគ្រោះនៃអំពើ ទាំងឡាយនោះផងដែរ"*។ ប៉ុន្តែទន្ទឹមនឹងនេះដែរ គឺថា **ឌុច** *"មិនបានទទួលយកការទទួលខុសត្រូវចំពោះអំពើ ដែលបានកើតឡើងនៅក្នុងមន្ទីរស-២១ នោះទាំងស្រុងឡើយ ដោយថា អ្វីៗគាត់ធ្វើតាមបញ្ជាពីថ្នាក់លើរបស់គាត់ដែលជាច្រើនលើកជាច្រើនសា គាត់បាននិយាយ យោងទៅលើឈ្មោះ* ***នួន ជា*** *(បច្ចុប្បន្នកំពុងដាក់ឱ្យនៅក្នុងមន្ទីរឃុំខ្លួនបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីរង់ចាំការកាត់ទោសផងដែរ)* និង ***សុន សេន*** *(បានស្លាប់ទៅហើយ)"*។

ខាងក្រោមនេះ គឺជាសំរង់ទិដ្ឋភាពសំខាន់ៗមួយចំនួនដែលបានកើតឡើង នៅក្នុងសវនាការដែលបានកើតមានឡើងនៅក្នុងអំឡុងត្រឹមខែឧសភានេះ

## ❖ ការចូលរួមរបស់តំណាងអយ្យការ និងក្រុមមេធាវីការពារ:

ក្រុមតំណាងអយ្យការ គឺជាក្រុមសហព្រះរាជអាជ្ញាដែលមានតួនាទីសំរាប់ធ្វើការដាក់បន្ទុកទៅលើជនជាប់ចោទក្នុងនោះ រួមមានសហព្រះរាជអាជ្ញារងជាតិ (លោក **យ៉េត ចរិយា** និង លោក **តាន់ សេណារ៉ុង**) និង សហព្រះរាជអាជ្ញារងអន្តរជាតិ (លោក **អាឡិច បេត**- Alex Bates)។ ចំណែកសហមេធាវីការពារជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** គឺរួមមានលោក **ការ សាវុត្ថ** និងលោក **ហ្វ្រង់ស្វ័រ រូហ៍** (មេធាវីជនជាតិបារាំង)។



*ជនជាប់ចោទ* ***កាំង ហ្គេកអ៊ាវ*** *ហៅ* ***ឌុច***

## ❖ បញ្ហាទាក់ទិននឹងសំណុំរឿងដែលបានលើកយកឡើង:

- *ការបង្កើត និងរចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរស-២១*: មានការចោទសួរដោយផ្ទាល់ពីសំណាក់ចៅក្រម ទៅលើជនជាប់ចោទ អំពី: ការបង្កើត និងរចនាសម្ព័ន្ធគ្រប់គ្រងនៅមន្ទីរស-២១ ដោយសារថា មន្ទីរស-២១ នេះ គឺជាកម្មវត្ថុសំខាន់មួយ នៅក្នុងចំណោមមន្ទីរសន្តិបាលផ្សេងទៀត ដែលភ្ជាប់ការទទួលខុសត្រូវរបស់ជនជាប់ចោទទៅនឹងឧក្រិដកម្មដែលបានកើតឡើង។ ទាក់ទិននឹងការលើកឡើងអំពីចំណុចនេះ ក៏មានការនិយាយពាក់ព័ន្ធនឹងគោលដៅនៃការបង្កើត, ទីតាំងមន្ទីរស-២១ និង រចនាសម្ព័ន្ធគ្រប់គ្រង និងសកម្មភាពនានាដែលបានកើតឡើងរួមបញ្ចូលទាំង ការធ្វើទារុណកម្ម ការសំលាប់ និង ការប្រព្រឹត្តអំពើបែបអមនុស្សធម៌ដទៃទៀតផងដែរ។
- *ការអនុវត្តន៍នូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា*: ចៅក្រមសាលាដំបូងក៏បានចោទសួរច្រើនសំណួរទៅកាន់ **ឌុច** អំពីការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រែក្លាយប្រទេសកម្ពុជាឱ្យធ្លាប់ទៅក្នុងវិនាសកម្មដ៏សែនអាណោចអាធ័មនេះ។ ទាក់ទិននឹងការចោទសួររបស់ចៅក្រមនេះ ជនជាប់ចោទ **ឌុច** បាននិយាយថា គាត់បានជឿជាក់ទៅលើទស្សនៈសង្គមនិយមនិងលេនីននិយម តាំងតែពីកាលពីគាត់នៅយុវវ័យមកម្ល៉េះ ប៉ុន្តែវាបានប្រែក្លាយទៅតំណក់ឈាមទៅវិញនៅពេលកម្ពុជាប្រជាធិបតេយ្យកាន់កាប់

អំណាច។ **ឌុច** បានបន្តនិយាយប្រាប់ចៅក្រមសាលា ដំបូងថា *"សមាជិកបក្ស ត្រូវបានលើកទឹកចិត្តឱ្យមានជំហររឹងមាំចំពោះសត្រូវដើម្បីធ្វើឱ្យយ៉ាងណាឱ្យបក្សបរិសុទ្ធ និងស្អាតស្អំ"*។ ប៉ុន្តែអត្ថន័យ នៃពាក្យថា *"សត្រូវ"* នេះមានការប្រែប្រួលទៅតាមពេលវេលារហូត។ ជនជាប់ ចោទរូបនេះ បានបន្ថែមទៀតថា ប៉ុល ពត ដែលជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ បានដឹកនាំបែប**កុម្មុនីស្តប៉ុល ពត និយម** ដែលជ្រុលលើសពីទ្រឹស្តី**កុម្មុយនីស្តបែបម៉ៅនិយម**របស់ចិនទៅទៀត។ លើសពីនេះទៅទៀត **ឌុច** ក៏បានបញ្ជាក់ផងដែរថា មានមនុស្ស ៤ក្រុម ដែលមានអំណាចក្នុងការបញ្ជាឱ្យធ្វើវិសុទ្ធកម្ម ឬកំទេចក្នុងកំឡុងពេលធ្វើវិសុទ្ធកម្មដែលក្នុងនោះរួមមានដូចជា: គណៈកម្មាធិការអចិន្ត្រៃយភូមិភាគ, គណៈការិយាល័យមជ្ឈឹមបក្ស, គណៈកម្មាធិការអចិន្ត្រៃយ៍ និងនាយសេនាធិការ។

❖ **ការផ្តល់កស្សិណ ឬសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញសំខាន់ៗ:**

- *អ្នកជំនាញលោក* ***ក្រេច អេជីសុន*** : ក្នុងឋានៈជាអ្នកជំនាញម្នាក់ លោក **ក្រេច អេជីសុន** ដែលជាអ្នកស៊ើបអង្កេតមួយរូបនៅក្នុងសាលាក្តីខ្មែរក្រហម បានផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុង សវនាការនេះពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ គោលនយោបាយ មនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ។ ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម លោកស្រី **ស៊ីលវើ ខាត់រ៉ាយ៍** អំពីបញ្ហាវិសុទ្ធកម្ម (ការសំអាតផ្ទៃក្នុង) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោក **អេជីសុន** បានលើកឡើងថា *"វាមានការធ្វើវិសុទ្ធកម្ម/សំអាតធ្វើឡើងជាលក្ខណៈទូលំទូលាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ មានបុគ្គលិកកម្មាភិបាលខ្លះត្រូវបានគេយកទៅសំលាប់ នៅក្នុងអង្គភាពរបស់ខ្លួន ហើយខ្លះទៀត ត្រូវបានបញ្ជូនទៅកន្លែងធ្វើការជាទំងន់ឬបញ្ជូនមកមន្ទីរស-២១។"* នៅក្នុងចំណុច ឆ្លើយបំភ្លឺរបស់អ្នកជំនាញរូបនេះ ក៏ត្រូវបានជំទាស់លើចំណុចមួយចំនួនដោយសហមេធាវីការពារក្តី គឺលោក **ហ្វ្រង់ស្វ័រ រូហ៉ា** ផងដែរ ដោយសារមេធាវីជំទាស់ថា មានចំណុចខ្លះដែលបានលើកឡើង គឺមិនស្ថិតនៅរបៀបវារៈ ដែលត្រូវផ្តល់សក្ខីកម្មនាពេលសវនាការពេលនោះឡើយ។

❖ **ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជនៈ**

មានជនរងគ្រោះជាច្រើន ដែលបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនីតិវិធី និងដើម្បីទាមទារនូវសំណងរដ្ឋប្បវេណីនៅពេលខាងមុខ។ នៅក្នុងសំណុំរឿងលេខ០០១ ប្រឆាំងនឹងជនជាប់ចោទឈ្មោះ **ឌុច** នេះ មានដើមរដ្ឋប្បវេណីចំនួន ៩៤រូប ដែលត្រូវបានទទួលស្គាល់ និងត្រូវបានតំណាង ដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ក្រុម ដែលមានចំរុះជាតិសាសន៍ (ជាតិ និងអន្តរជាតិ ក្រោមការជួយសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គភាពជនរងគ្រោះ)។

ការពិត គេសង្កេតឃើញមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនតិចតួចប៉ុណ្ណោះ ដែលបានចូលរួមជាប្រចាំនៅក្នុងបន្ទប់សវនាការ ដើម្បីតាមដាននូវដំណើរការកាត់សេចក្តីនេះ ក៏ដូចជាតាមដានស្តាប់ការឆ្លើយបំភ្លឺរបស់ជនជាប់ចោទ **ឌុច**។ ការដែលមិនអាចចូលរួមឱ្យពេញលេញរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺអាចមូលហេតុមកពីពួកគេមិនមានថវិកាសំរាប់មកចូលរួម និងការប្រគល់សិទ្ធិជាតំណាងផ្លូវច្បាប់ដល់មេធាវីរួចរាល់ហើយ។

ដោយឡែក ចំពោះសាធារណជនទូទៅវិញ គឺគេសង្កេតឃើញមានវត្តមានជាច្រើនប្រមាណ ១៥០-២៥០នាក់ នៅរៀងរាល់សប្តាហ៍ ទាំងសាធារណជនជាតិ និងអន្តរជាតិ។ ក្នុងចំណោមអ្នកទាំងនោះ គឺ មានប្រជាជនមកពីខេត្ត និស្សិត បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមានចំណាប់អារម្មណ៍តាមដានព្រឹត្តិការណ៍កាត់សេចក្តីជាប្រវត្តិសាស្ត្រនេះ។

គួរបញ្ជាក់ថា រហូតមកទល់ពេលនេះ សវនាការទៅលើសំណុំរឿងរបស់អតីតមេគុកទួលស្លែងនេះនៅមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ដោយមូលហេតុថា នៅមានសាក្សី និងអ្នកជំនាញជាច្រើនដែលនឹងត្រូវកោះអញ្ជើញ ដើម្បីមកឆ្លើយបំភ្លឺ និងផ្តល់សក្ខីកម្មបន្ថែមទៀត ព្រមទាំងភស្តុតាងផ្សេងទៀត ក៏នឹងត្រូវបង្ហាញដោយភាគីនៅក្នុងរឿងក្តីដែរ។

ជាការកត់សំគាល់ផងដែរ នៅខណៈពេលដែលមានសវនាការ ទៅលើ **ឌុច** នេះ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ កន្លងទៅ អង្គបុរេជំនុំជម្រះ នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសាលដីកាបដិសេធនឹងសំណើសុំនៅក្រៅឃុំជាលើកទី២ របស់ជនត្រូវចោទ **អៀង ធីរិទ្ធិ** ដែលធ្លាប់ជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការសំរេចបដិសេធការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នធ្វើឡើងស្របតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នឆ្នាំទី២ ដោយសហចៅក្រមស៊ើបអង្កេត ៕

# អំពើហិង្សាខាងផ្លូវភេទក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

## Gender-based Crimes under the Democratic Kampuchea

ប្រទេសម្ពុជា បានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលជិតបួនឆ្នាំ ហើយប្រជាជនកម្ពុជាបានបាត់បង់ជីវិតប្រមាណជាង១លាននាក់ ដោយការកាប់សំលាប់ ការបង្ខំអោយធ្វើការជាទម្ងន់ ការបង្អត់អាហារ និងការស្លាប់ដោយសារជំងឺ ជាដើម ក្នុងនោះក៏មានទាំងអ្នកត្រូវគេសម្លាប់ក្នុងរឿងទំនាក់ទំនងផ្លូវភេទ និងអ្នកត្រូវគេរំលោភផ្លូវភេទមុននឹងត្រូវគេសម្លាប់ផងដែរ ។ ទន្ទឹមនឹងនោះ អ្នកនៅរស់រានមានជីវិតមួយចំនួន ក៏បានទទួលរងនូវអំពើទារុណ្ណកម្មផ្សេងៗ ការរំលោភ ការយាយីលើរាងកាយ រួមទាំងមាន ការបង្ខំឱ្យរៀបការទាំងហ្វូងៗទៀតផង ។ សព្វថ្ងៃនេះ ពួកគាត់ទាំងអស់គ្នាបានទន្ទឹងរង់ចាំការផ្តល់យុត្តិធមិតាមរយៈតុលាការមួយឯករាជ្យមិនលំអៀង ។

មកដល់ពេលបច្ចុប្បន្ននេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាបានឃុំខ្លួនមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវជាន់ខ្ពស់បំផុតនៃរបបកម្ពុជាជាប្រជាធិបតេយ្យចំនួន ០៥ នាក់ផងដែរ ក្នុងនោះមាន ម្នាក់ដែលជាអតីតប្រធានគុកទួលស្លែង ឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** បានត្រូវអង្គជំនុំជម្រះសាលាដំបូងកំពុងដំណើរការសវនាការកាត់សេចក្តី ។ ចំណែកអតីតមមេដឹកនាំខ្មែរក្រហម៤រូបផ្សេងទៀត ដែលបច្ចុប្បន្នបានត្រូវឃុំខ្លួនបណ្តោះអាសន្ននោះ រួមមាន លោក **នួន ជា** ( អតីតប្រធានសភា) លោក **ខៀវ សំផន** ( អតីតប្រធានគណៈប្រធានរដ្ឋ) លោក **អៀង សារី** ( អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងការបរទេស) និងលោកស្រី **អៀង ធីរិទ្ធិ** ( អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច) ។

ស្របពេលដែលសាលាក្តីនេះកំពុងដំណើរការនិតិវិធីរបស់ខ្លួន អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានចាប់ផ្តើមនូវគំរោងថ្មីមួយទៀតគឺ កម្មវិធី ***អំពើហិង្សាខាងផ្លូវភេទក្រោមរបបកម្ពុជាប្រជាធិបតេយ្យ*** ដែលបានកើតឡើងពី ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ១៩៧៩ ។ គំរោងនេះ អនុលោមតាមសំណើរបស់ គណៈកម្មាធិការស្រ្តីកម្ពុជា (CAMBOW) ដោយមានដាក់ចេញនូវគោលបំណងសំខាន់ៗ ដូចខាងក្រោមៈ

១- បង្កើនការយល់ដឹង និងតស៊ូមតិពីអំពើឃោរឃៅទាក់ទងនឹង ការរំលោភផ្លូវភេទ ការយាយីលើរាងកាយ ឬការធ្វើទារុណ កម្មផ្លូវភេទ និងការបង្ខំអោយរៀបការជាដើម ។ អំពើទាំងនេះ បានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាបទឧក្រិដ្ឋមួយដ៏ធ្ងន់ធ្ងរប្រឆាំងនឹង មនុស្សជាតិដែលត្រូវដាក់ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

២- លើកទឹកចិត្ត និងជួយសំរួលដល់ជនរងគ្រោះ និងសាក្សីនានា ដែលមានបំណងចង់ចូលរួមក្នុងដំណើរការនិតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយជួយរកនូវមេធាវី ឬតំណាងជូនដល់ពួកគាត់ ។

### សំណូមពរៈ

ដោយកន្លងមកបញ្ហាឃោរឃៅទាក់ទងនឹងផ្លូវភេទដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះហាក់ ដូចជាមិនសូវមានការយកចិត្តទុកដាក់ជាទូទៅ អោយបានខ្លាំងក្លាពីសាធារណជននៅឡើយទេ ។ ដូច្នេះ សំណូមពរដល់អង្គការនានា ព្រមទាំងស្ថាប័ន ដែលមានការពាក់ព័ន្ធ សូមជួយលើកទឹកចិត្ត គាំទ្រ និងសហការលើការងារនេះអោយបានទូលំទូលាយ ។ ទន្ទឹមនឹងនោះក៏សូមលើកទឹកចិត្តជនរងគ្រោះ និងសាក្សី ព្រមទាំងជនកម្ពុជាទាំងអស់ចូលរួមក្នុងសាលាក្តីនេះអោយកាន់តែសកម្មថែមទៀត ។ បើពុំដូច្នោះទេយុត្តិធម៌ក៏មិនបានមកដោយឯកឯងដល់ជនរងគ្រោះ និងយើងទាំងអស់គ្នានោះដែរ ។

ដូចនេះ ប្រសិនបើជនរងគ្រោះជួបប្រទះបញ្ហាខាងលើនេះហើយ ត្រូវការដាក់ពាក្យបណ្តឹង ឬចង់ដឹងព័តិមានលំអិតសូមទាក់ទងមកកាន់គណៈកម្មាធិការយើង តាមរយៈទូរស័ព្ទ ០១២ ៨០០ ៨១៦ ឬ ០២៣ ៧២០ ០៣២ ។

### ព័ត៌មានសំខាន់:

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៏ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

**សូមទាក់ទង:**

- **សមាគមអាដហុក (ADHOC)**
  លេខទូរស័ព្ទ: ០២៣ ៩៩០ ៥៤៤, ០២៣ ២១៨ ៦៥៣
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ **(KID)**
  លេខទូរស័ព្ទ: ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម **(CSD)**
  លេខទូរស័ព្ទ: ០២៣ ៣៦៤ ៧៣៥
- អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស **(KKKHRO)**
  លេខទូរស័ព្ទ: ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១

➢ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័តិមានបន្ថែមលើគេហទំព័រ www.krtrial.info

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(NED) និង ឌី.អ៊ី.ឌី(DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**

The National Endowment for Democracy — Supporting freedom around the world

ded Deutscher Entwicklungsdienst